ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែសីហា និងទិសដៅការងារខែកញ្ញា ឆ្នាំ២០២៤

នៅក្នុងខែសីហានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារលើគ្រប់វិស័យ ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖

### ១-មុខងារតាមដានការអនុវត្តច្បាប់

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនគណៈកម្មការនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្ម នៅតាមបណ្តារាជធានី ខេត្ត ក្រុងនានា រួមមាន៖
  - គណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចុះបំពេញបេសកកម្មដើម្បីសិក្សាស្វែងយល់ និងប្រមូលព័ត៌មានអំពីការផ្សព្វផ្សាយច្បាប់ និងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តព្រៃវែង។
  - គណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចុះបំពេញបេសកកម្មដើម្បីសិក្សាស្វែងយល់ និងប្រមូលព័ត៌មានអំពីការផ្សព្វផ្សាយច្បាប់ និងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តស្វាយរៀង និង
  - គណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញចុះបំពេញបេសកកម្មដើម្បីសិក្សាស្វែងយល់ និងស្រង់ព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ រួមមាន៖ ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ច វឌ្ឍនភាពការងារ និងបញ្ហាប្រឈម នៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការអភិវឌ្ឍមូលដ្ឋាន ព្រមទាំងសំណូមពរនានា ដែលខេត្តបានជួបនាពេលកន្លងទៅ និងពេលបច្ចុប្បន្ន នៅសាលប្រជុំសាលាខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម។



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

## ២-មុខងារតំណាង

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា បាន៖**

- អញ្ជើញចូលរួមដង្ហែព្រះរាជដំណើររបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គសព្វព្រះរាជហឫទ័យ ស្តេចយាងទៅបំពេញព្រះរាជទស្សនកិច្ចនៅតំបន់ស្វយ័ត Xinjiang Uyghur នៃសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
- អញ្ជើញចូលរួមទទួលព្រះរាជដំណើររបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គសព្វព្រះរាជហឫទ័យ ស្តេចយាងនិវត្តន៍មកពីបំពេញព្រះរាជទស្សនកិច្ចនៅតំបន់ស្វយ័ត Xinjiang Uyghur នៃសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
- អញ្ជើញចូលរួមដង្ហែព្រះរាជដំណើររបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ព្រះអង្គយាងទៅពិនិត្យព្រះរាជសុខភាព នៅសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
- ចេញសារសំឡេងពិសេស ពន្យល់បន្ថែមអំពីកិច្ចសហប្រតិបត្តិការតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម (CLV-DTA) និង
- ចេញសារសំឡេងពិសេស ផ្តាំផ្ញើដល់អភិបាលខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី រៀបចំទទួលដំណើរទស្សនកិច្ចរបស់ព្រះអង្គធម្មវនវាសីបណ្ឌិត **ចន្ទ មុនី** និមន្តទៅកាន់តំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម (CLV-DTA) ។

❖ **ឯកឧត្តម ប្រាក់ សុខុន ប្រធានស្តីទីព្រឹទ្ធសភា បាន៖**

- អញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំខេត្ត ក្រុង និងក្រុមប្រឹក្សាសង្កាត់ទាំង១២ របស់ក្រុងសៀមរាប និងក្រុមប្រឹក្សាឃុំទាំង៨ ដែលនៅជុំវិញក្រុងសៀមរាប ខេត្តសៀមរាប នៅសាលប្រជុំសាលាខេត្តសៀមរាប និង
- អញ្ជើញជាអធិបតីក្នុងពិធីដាំកូនឈើ ក្រោមប្រធានបទ " **ដាំដើមឈើ ដើម្បីបរិស្ថានស្អាតក្នុងក្រុងសៀមរាប** " នៅតាមបណ្តោយវិថី **ប៊ុន រ៉ានី ហ៊ុន សែន** ក្នុងក្រុងសៀមរាប ខេត្តសៀមរាប។

❖ **ឯកឧត្តម ច្រាក់ សុខុន អនុប្រធានទី១ព្រឹទ្ធសភា បាន៖**

- អញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំការងារ នៅសាលប្រជុំពិសេស៣ នៃវិមានព្រឹទ្ធសភា ចំនួន ៣លើក រួមមាន៖
    - កិច្ចប្រជុំឆ្លងសេចក្ដីព្រាងថវិកាព្រឹទ្ធសភាប្រចាំឆ្នាំ២០២៥ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
    - កិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ដើម្បីពិនិត្យ ពិភាក្សាលើរបាយការណ៍បូកសរុបលទ្ធផលការចុះស្វែងយល់អំពីបញ្ហាប្រឈម និងសំណូមពរនានា របស់មូលដ្ឋានទាំង១១ខណ្ឌ ក្នុងរាជធានីភ្នំពេញ និងប្រធានបទត្រៀមលក្ខណៈរៀបចំវេទិកាពិគ្រោះយោបល់ និង
    - កិច្ចប្រជុំការងារផ្ទៃក្នុងជាមួយសមាជិកខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា ។
- អញ្ជើញជួបសម្ដែងការគួរសម និងពិភាក្សាការងារជាមួយ**សម្ដេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានរដ្ឋសភា។
- អនុញ្ញាតថ្វាយ និងឱ្យភ្ញៀវជាតិ ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ នៅបន្ទប់ធ្វើការរបស់ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា ចំនួន ៣លើក រួមមាន៖
    - ឯកឧត្តម **សុខ ចិន្ដាសោភា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។
    - សម្ដេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា និង
    - ឯកឧត្តម **ម៉ម សារិន** ប្រធានក្រុមទីប្រឹក្សា**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា។
- អញ្ជើញចុះជួបសំណេះសំណាល និងចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ នៅតាមបណ្ដារាជធានី ខេត្ត ក្រុងនានា ចំនួន ៨លើក រួមមាន៖
    - អញ្ជើញចូលរួមដង្ហែព្រះរាជដំណើររបស់**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គសព្វព្រះរាជហឫទ័យ ស្ដេចយាងទៅបំពេញព្រះរាជទស្សនកិច្ចនៅតំបន់ស្វយ័ត Xinjiang Uyghur នៃសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
    - អញ្ជើញចូលរួមទទួលព្រះរាជដំណើររបស់ **ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គសព្វព្រះរាជហឫទ័យ ស្ដេចយាងនិវត្តន៍មកពីបំពេញព្រះរាជទស្សនកិច្ចនៅតំបន់ស្វយ័ត Xinjiang Uyghur នៃសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

- អញ្ជើញចូលរួមដង្ហែព្រះរាជដំណើររបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ព្រះអង្គយាងទៅពិនិត្យព្រះរាជសុខភាព នៅសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធី " **បើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ** " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិព្រែកតាកែវ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល។
- អញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងកម្មវិធីចាក់បញ្ចាំងភាពយន្ត " **ការណាត់ជួបគ្នាជាមួយ ប៉ុល ពត** " នៅរោងភាពយន្ត Legend Premium Cinema Exchange Square។
- អញ្ជើញដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ អញ្ជើញចុះជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំខណ្ឌ ក្រុមប្រឹក្សាសង្កាត់ទាំង៦ និងអាជ្ញាធរពាក់ព័ន្ធ នៅខណ្ឌសែនសុខ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដើម្បីពិគ្រោះយោបល់ និងរិះរកដំណោះស្រាយអំពីបញ្ហាប្រឈម ការលំបាក និងសំណូមពរផ្សេងៗ។
- អញ្ជើញនាំយកទៀនចំណាំព្រះវស្សា ទេយ្យទាន និងបច្ច័យ ទៅប្រគេនព្រះសង្ឃកំពុងគង់ចាំព្រះវស្សា នៅវត្តសុវណ្ណបទុម (វត្តចំបក់មាស) និងវត្តមង្គលសត្ថារ៉ែន (វត្តព្រែកតាគង់) ស្ថិតក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និង
- អញ្ជើញនាំយកទៀនចំណាំព្រះវស្សា ទេយ្យទាន និងបច្ច័យ ទៅប្រគេនព្រះសង្ឃកំពុងគង់ចាំព្រះវស្សា នៅវត្តអូរផែលតេជោមានជ័យ និងបានជួបសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ព្រមទាំងបានចែកថវិកាមួយចំនួនដល់សិស្សានុសិស្ស ក្នុងសាលាបឋមសិក្សាពូជ្រៃចម្ការកៅស៊ូ នៅភូមិពូតាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី។ ក្នុងឱកាសនោះឯកឧត្តម ក៏បានសម្រេចឧបត្ថម្ភថវិកា ចំនួន ៩៦០,០០០រៀល/១នាក់ ជារៀងរាល់ខែ ដល់អ្នកគ្រូបង្រៀន ចំនួន ២នាក់ ដែលបានខិតខំទៅបង្រៀនសិស្ស នៅតំបន់ដាច់ស្រយាលនេះ។

❖ ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី២ **ព្រឹទ្ធសភា** តំណាងដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** បានរៀបចំពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់អគារថ្មី នៃព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី២ព្រឹទ្ធសភា បាន៖**

- អញ្ជើញដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ដើម្បីត្រៀមលក្ខណៈក្នុងការរៀបចំកម្មវិធីចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាល អាជ្ញាធរមូលដ្ឋាន ខេត្តត្បូងឃ្មុំ នៅបន្ទប់ប្រជុំខុទ្ទកាល័យ អនុប្រធានទី២ព្រឹទ្ធសភា។
- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធី " **បើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ** " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិព្រែកតាកែវ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល។
- ចាត់ឱ្យក្រុមទីប្រឹក្សា និងទីប្រឹក្សាបច្ចេកទេស ចូលរួមទូងស្គរអបអរសាទរពិធី " **បើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ** " នៅមជ្ឈមណ្ឌលកុមារកំព្រាស្នាមញញឹមថ្មីនៃក្តីសង្ឃឹមរបស់កុមារ នៅភូមិក្រសាំង ឃុំដើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល និង
- ដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ អញ្ជើញចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ស្មៀន នាយប៉ុស្តិ៍នគរបាលឃុំ អាជ្ញាធរស្រុកអូររាំងឪ ស្រុកមេមត់ ស្រុកពញាក្រែក ស្រុកត្បូងឃ្មុំ និងក្រុងសួង ខេត្តត្បូងឃ្មុំ ចំនួន ៥០៤នាក់ ដើម្បីផ្សារភ្ជាប់ និងប្រាស្រ័យទាក់ទងឱ្យកាន់តែជិតស្និទ្ធជាមួយអង្គបោះឆ្នោត ពង្រឹងការអនុវត្តតួនាទីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ការផ្តល់សេវាសាធារណៈ ការងារអនុវត្តន៍គោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ដោះស្រាយសំណូមពរ និងស្វែងយល់បញ្ហាប្រឈមនានា ព្រមទាំងបាននាំយកអំណោយជាឱសថ ចំនួន ១៣មុខ ដែលជាជំនួយមនុស្សធម៌របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ប្រគល់ជូនមន្ទីរពេទ្យបង្អែកស្រុកមេមត់ ខេត្តត្បូងឃ្មុំ សម្រាប់ប្រើប្រាស់នៅក្នុងមន្ទីរពេទ្យ។

❖ **សមាជិក សមាជិកាព្រឹទ្ធសភាបាន៖**

- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន ៤លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា រួមមាន៖ ពិធី " **បើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ** " ពិធីសម្ពោធបើកដំណើរការជាផ្លូវការសាកលវិទ្យាល័យ **ឌី ម៉ុនហ្វតកម្ពុជា** ពិធីសំណេះសំណាលជាមួយអាចារ្យ អាចារិនី ទូទាំងប្រទេសលើកទី៩ ចំនួន ១,០០០នាក់ និងពិធីទទួលវត្ថុបុរាណខ្មែរ ដែលបានប្រគល់ជូនព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅរាជធានីភ្នំពេញ និងខេត្តកណ្តាល។
- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់អគារថ្មី នៃព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី២ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។

- អញ្ជើញចូលរួមកិច្ចប្រជុំស្ដីពី វឌ្ឍនភាពការងារយុវជនកាកបាទក្រហមកម្ពុជា និងទិសដៅការងារបន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** អនុប្រធានអចិន្ត្រៃយ៍កាកបាទក្រហមកម្ពុជា នៅរាជធានីភ្នំពេញ។
- អញ្ជើញចូលរួមជាអធិបតីក្នុងកិច្ចពិភាក្សាការងារជាមួយអង្គបោះឆ្នោត នៅតាមមូលដ្ឋាន អំពី " ការចុះបញ្ជីអត្រានុកូលដ្ឋាន " ក្រោមអធិបតីភាពរបស់លោកជំទាវ **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា នៅសាលប្រជុំសាលាក្រុងសំពៅពូន និងស្រុកកៀនស្វាយ ខេត្តកណ្ដាល ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សមាជិក សមាជិកាក្រុមប្រឹក្សា ក្រុង ស្រុក ឃុំ សង្កាត់ ស្មៀន និងអាជ្ញាធរមានសមត្ថកិច្ច ព្រមទាំងមន្ត្រីពាក់ព័ន្ធសរុប ចំនួន ៦០នាក់។
- អញ្ជើញចូលរួមជាកិត្តិយសក្នុងកម្មវិធី "ទិវាជាតិអន្តរសាសនា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សលើកទី៨ ឆ្នាំ២០២៤" ក្រោមអធិបតីភាពរបស់**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅរាជធានីភ្នំពេញ។
- អញ្ជើញជាអធិបតីក្នុងសិក្ខាសាលាស្ដីពី ការស្វែងយល់ពីការអភិវឌ្ឍសេដ្ឋកិច្ច នៅតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម (CLV-DTA) នៅសាលប្រជុំធំ នៃវិទ្យាស្ថានជាតិកសិកម្ម ព្រែកលៀប រាជធានីភ្នំពេញ។
- អញ្ជើញជាគណៈអធិបតីក្នុងទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ខួបលើកទី១៦១ ក្រោមប្រធានបទ "រួមគ្នាជាមួយកាកបាទក្រហមកម្ពុជា ដើម្បីសហគមន៍មានសុខភាពល្អ និងមានភាពធន់នឹងអាកាសធាតុ" នៅសាលប្រជុំសាលាខេត្តកំពង់ឆ្នាំង។
- អញ្ជើញជាអធិបតី និងជាអ្នកសម្របសម្រួលក្នុងសិក្ខាសាលាពិគ្រោះយោបល់លើរបាយការណ៍ស្ដីពី " ការវិភាគលើលក្ខណៈក្រៅប្រព័ន្ធ នៃអនុវិស័យកសិ-ចំណីអាហារ ដំឡូងមី និងស្វាយចន្ទី " រៀបចំដោយអង្គការអាយឡូ (ILO) នៅសណ្ឋាគារហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ។
- អញ្ជើញជាអធិបតីក្នុងពិធីដាំកូនឈើ ក្រោមប្រធានបទ " ការបណ្ដុះផ្នត់គំនិតពន្លកបៃតង " នៅបរិវេណវត្តចំបក់បិទមាស និងនៅសាលាបឋមសិក្សាកន្ទុយរ៉ៃ ខេត្តស្វាយរៀង។
- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីឆ្លង និងសម្ពោធសមិទ្ធផលនានា នៅវត្តបារាយណ៍ ស្ថិតក្នុងក្រុងដូនកែវ ខេត្តតាកែវ។
- អញ្ជើញធ្វើបាឋកថាស្ដីពី " តើកម្ពុជាបានអភិវឌ្ឍន៍សេដ្ឋកិច្ចបានល្អកម្រិតណា " នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមពិធីបិទវគ្គបណ្ដុះបណ្ដាលបច្ចេកទេសជំនាញការដំឡើងបណ្ដាញអគ្គិសនីក្នុងអគារ នៅវិទ្យាល័យជប់វ៉ារី ខេត្តបន្ទាយមានជ័យ។
- អញ្ជើញចូលរួមក្នុងពិធីបើកវេទិកាយុវជន-បញ្ញវន្តមុស្លីម២១ ឆ្នាំ២០២៤ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបើកការប្រកួតកីឡាទូកប្រពៃណីខ្នាតអន្តរជាតិ " ទូកនាគ ទូកកានូ ទូកកាយ៉ាក់ និងទូករ៉ូអ៊ុង " ដើម្បីជ្រើសរើសជើងឯកថ្នាក់ជាតិ

៣នរង្វាន់**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** លើកទី១ ឆ្នាំ២០២៤ នៅទន្លេវ៉ៃគោ ខេត្តស្វាយរៀង។

- អញ្ជើញចូលរួមក្នុងពិធីអបអរសាទរខួបលើកទី៩៧ នៃការបង្កើតកងទ័ពរំដោះប្រជាជនចិន នៅសណ្ឋាគារសាន់ &មូន រីវើសាយ រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមវេទិកាសាធារណៈជាមួយអភិបាលស្រុក ក្រុមប្រឹក្សាស្រុក និងមន្ទីរ ការិយាល័យជំនាញស្តីពី តម្រូវការដាក់ស្តែង កង្វល់ បញ្ហាប្រឈមនានា របស់ប្រជាពលរដ្ឋ នៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។
- អញ្ជើញទស្សនកិច្ចសិប្បកម្មតម្បាញ ហូល ផាមួង ក្រមា មួក និងផលិតផលកែច្នៃដោយដៃ នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ **ប៊ុន រ៉ានី ហ៊ុន សែន** ខេត្តពោធិ៍សាត់។
- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារសិក្សាចំនួន ១ខ្នង នៅ វិទ្យាល័យល្វា ស្ថិតក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម។
- អញ្ជើញចុះពិនិត្យការដ្ឋានជួសជុលផ្លូវមួយខ្សែ ចាប់ពីផ្លូវជាតិលេខ ៥៦អា ដល់វត្តរលំជ្រៃ ឃុំភូមិថ្មី ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។
- អញ្ជើញនាំយកអំណោយជាឱសថ ចំនួន ១១មុខ ដែលជាជំនួយមនុស្សធម៌របស់មូលនិធិ ចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ប្រគល់ជូនមន្ទីរពេទ្យបង្អែក ស្រុកតំបែរ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ និងស្រុកស្ទឹងត្រង់ ស្រុកចំការលើ ខេត្តកំពង់ចាម។
- អញ្ជើញសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃសមាគមបេសកកម្មមនុស្សធម៌ នៅកម្ពុជា(AMH) របស់សាធារណរដ្ឋបារាំង អញ្ជើញចុះពិនិត្យ និងព្យាបាលជំងឺទូទៅ ជូនប្រជាពលរដ្ឋ ដោយឥតគិតថ្លៃ នៅខេត្តតាកែវ ខេត្តព្រៃវែង និងខេត្តស្វាយរៀង។
- អញ្ជើញនាំយកអំណោយដ៏ថ្លៃថ្លារបស់សម្តេចព្រះរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** ក្រុមសមាជិកាព្រឹទ្ធសភា សមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ និង របស់ក្រុមហ៊ុន SOPCO រួមមាន៖ ចង្ក្រានសន្សំសំចៃថាមពល ធុងចម្រោះទឹកស្អាត ក្រមា និងសាប៊ូលាងសំអាតដៃ ចែកជូនប្រជាពលរដ្ឋ ចំនួន ២៦៥គ្រួសារ មកពី ឃុំទាំង៨ ក្នុងស្រុកកញ្ច្រៀច ខេត្តព្រៃវែង។
- អញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាល និងចែកចង្ក្រានសន្សំសំចៃថាមពល ព្រមទាំង ដបទឹករក្សាកម្តៅជូនប្រជាពលរដ្ឋ នៅឃុំកន្សោមអក ឃុំព្រៃឈរ ស្រុកកំពង់ត្របែក និង ស្រុកកំចាយមារ ខេត្តព្រៃវែង។
- អញ្ជើញនាំយកថវិកាឧបត្ថម្ភជូននិស្សិតដែលត្រូវទៅបន្តការសិក្សានៅប្រទេសអេហ្ស៊ីប ចំនួន ៥នាក់ និងសាធារណរដ្ឋឥណ្ឌូណេស៊ី ចំនួន ៦នាក់ នៅសង្កាត់សំបួរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម និងបានអនុញ្ញាតឱ្យប្អូនៗនិស្សិតដែលត្រូវទៅបន្តការសិក្សា នៅសាធារណរដ្ឋឥណ្ឌូណេស៊ី ចូលជួបសម្តែងការគួរសម និងសុំអនុសាសន៍ណែនាំ។
- អញ្ជើញចែកធុងចម្រោះទឹកស្អាត ជូនប្រជាពលរដ្ឋ ចំនួន ២៣០គ្រួសារ នៅឃុំតាសួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។

- អញ្ជើញចូលរួមពិធីប្រគល់អង្ករ និងគ្រឿងឧបភោគ បរិភោគ ជូនមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត នៅស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២៤ និងទិសដៅអនុវត្តន៍បន្តរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ។
- អញ្ជើញចូលរួមជាមួយសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ រួមសហការជាមួយអនុសាខាកាកបាទក្រហមកម្ពុជា ខណ្ឌទួលគោក អញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយជូនប្រជាពលរដ្ឋចាស់ជរា និងជនពិការមានជំងឺរស់នៅក្នុងសង្កាត់ទាំង៧ ក្នុងខណ្ឌទួលគោក រាជធានីភ្នំពេញ។
- អញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាល និងចែកអំណោយជូនដល់ប្រជាពលរដ្ឋទីទាល់ក្រ ចំនួន ៥០គ្រួសារ នៅសង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដែលជាជំនួយសប្បុរសជនប្រទេសម៉ាឡេស៊ី តាមរយៈស្ថានទូតម៉ាឡេស៊ី។
- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាល និងបើកប្រាក់ឧបត្ថម្ភគោលនយោបាយលើកដំបូង ជូនដល់យោធិនសោធននិវត្តន៍ គណៈយុទ្ធមិត្តចូលបម្រើកងទ័ពជំនាន់ឆ្នាំ១៩៧៨ ចំនួន ៦៦៧នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៅទីបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តស្វាយរៀង។
- អញ្ជើញជួបសំណេះសំណាល ដើម្បីស្វែងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តតួនាទី ភារកិច្ច ក្នុងការអនុវត្តច្បាប់ និងផ្តល់សេវាសាធារណៈ ដោយផ្តោតសំខាន់លើការផ្តល់សេវារដ្ឋបាល ការងារស្ថិតិប្រជាពលរដ្ឋពាក់ព័ន្ធនឹងសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ការងារអត្រានុកូលដ្ឋាន និងការកែតម្រូវអក្ខរាវិរុទ្ធ ការងារមូលនិធិអភិវឌ្ឍឃុំ សង្កាត់ ការអនុវត្តគោលនយោបាយឃុំ សង្កាត់ មានសុវត្ថិភាព បញ្ហាប្រឈម តម្រូវការ និងសំណូមពរនានា ជុំវិញការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ក្រោមអធិបតីភាពរបស់ឯកឧត្តម **ប៉ុល លឹម** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ស្ថិតនៅសាលាក្រុងសៀមរាប ខេត្តសៀមរាប។
- អញ្ជើញជួបសំណេះសំណាល ដើម្បីសិក្សាស្វែងយល់អំពីការផ្តល់សេវាសាធារណៈ ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការងារកសាងផែនការ និងការងារអភិវឌ្ឍន៍មូលដ្ឋាន បញ្ហាប្រឈម និងសំណូមពរនានា ក្រោមអធិបតីភាពរបស់ឯកឧត្តម **ម៉ុង ឫទ្ធី** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ នៅសាលប្រជុំខេត្តព្រះសីហនុ និង
- អញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី ចំនួន ១១៣នាក់ នៅខេត្តកំពង់ធំ។

- ដោយឡែកសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន យុវជន យុវនារី ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅមូលដ្ឋាន ស្វែងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខ សណ្តាប់ធ្នាប់ ការអភិវឌ្ឍមូលដ្ឋាន ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយនានា ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ ជាពិសេសការដឹកស្តារប្រព័ន្ធធារាសាស្ត្រ និងការដាំកូនឈើ អញ្ជើញនាំយកអំណោយ គ្រឿងឧបភោគ បរិភោគ និងថវិកា ជូនប្រជាពលរដ្ឋដែលកំពុងខ្វះខាត ដោះស្រាយបញ្ហាប្រឈមនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ចំនួន ១២៦លើក ព្រមទាំងបានអញ្ជើញជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ ចំនួន ១២០លើក។
- ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងឯកឧត្តម **ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមអមដំណើរ ឯកឧត្តម **ប្រាក់ សុខុន** ប្រធានស្តីទីព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំខេត្ត ក្រុង និងក្រុមប្រឹក្សាសង្កាត់ទាំង១២ របស់ក្រុងសៀមរាប និងក្រុមប្រឹក្សាឃុំទាំង៨ ដែលនៅជុំវិញក្រុងសៀមរាប ខេត្តសៀមរាប និងក្នុងពិធីដាំកូនឈើ ក្រោមប្រធានបទ " **ដាំដើមឈើដើម្បីបរិស្ថានស្អាតក្នុងក្រុងសៀមរាប** " នៅតាមបណ្តោយវិថី **ប៊ុន រ៉ានី ហ៊ុន សែន** ក្នុងក្រុងសៀមរាប ខេត្តសៀមរាប។
- ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា ឯកឧត្តម **ខេង សិទ្ធិគុណ** ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា និងគណៈប្រតិភូ បានអញ្ជើញចូលរួមអមឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញនាំយកទៀនចំណាំព្រះវស្សា ទេយ្យទាន និងបច្ច័យ ទៅប្រគេនព្រះសង្ឃកំពុងគង់ចាំព្រះវស្សា នៅវត្តសុវណ្ណបទុម (វត្តចំបក់មាស) និងវត្តមង្គលសត្ថាវ័ន (វត្តព្រែកតាគង់) ស្ថិតក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
- ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បាន៖
  - អញ្ជើញចូលរួមអមឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ អញ្ជើញចុះជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំខណ្ឌ ក្រុមប្រឹក្សាសង្កាត់ និងអាជ្ញាធរពាក់ព័ន្ធ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដើម្បីពិគ្រោះយោបល់ និងរិះរកដំណោះស្រាយអំពីបញ្ហាប្រឈម ការលំបាក និងសំណូមពរផ្សេងៗ និង
  - អញ្ជើញជួបសំណេះសំណាល និងផ្តល់អនុសាសន៍ដល់មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ១២នាក់ ដែលនឹងត្រូវទៅចូលរួមវគ្គបណ្តុះបណ្តាលនៅសាធារណរដ្ឋប្រជាមានិតចិន។

❖ ឯកឧត្តម **ខេង សិទ្ធិគុណ** និងឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមអមឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ អញ្ជើញចុះជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំខណ្ឌ ក្រុមប្រឹក្សាសង្កាត់ទាំង៦ និងអាជ្ញាធរពាក់ព័ន្ធ នៅខណ្ឌសែនសុខ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដើម្បីពិគ្រោះយោបល់ និងរិះរកដំណោះស្រាយអំពីបញ្ហាប្រឈម ការលំបាក និងសំណូមពរផ្សេងៗ។

❖ ឯកឧត្តម **ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំការងារនៅរាជធានីភ្នំពេញ ចំនួន ៤លើក និង

❖ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃសមាគមបេសកកម្មមនុស្សធម៌នៅកម្ពុជា(AMH) របស់សាធារណរដ្ឋបារាំង អញ្ជើញចុះពិនិត្យ និងព្យាបាលជំងឺ ជូនប្រជាពលរដ្ឋ ដោយឥតគិតថ្លៃ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

- ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានប្រារព្ធពិធីទូងស្គរអបអរសាទរចំពោះព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ នៃពិធី " **បើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ** " នៅមុខសាលខាងជើងព្រឹទ្ធសភា។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់ព្រឹទ្ធសភា ក្នុងឱកាសដ៏ថ្លៃថ្លា និងជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររបស់ព្រះរាជាណាចក្រកម្ពុជា នៃពិធី " **បើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ** " ដែលជាគម្រោងផ្តល់ផលប្រយោជន៍ដ៏មហាសាលដល់សង្គម សេដ្ឋកិច្ចកម្ពុជា ដែលនឹងប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវបណ្ឌិត** និងចំពោះ " **សមិទ្ធផលជាច្រើនដែលសម្រេចបានក្នុងរយៈពេល ១ឆ្នាំ របស់រាជរដ្ឋាភិបាល នីតិកាលទី៧** " ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។
- បានចាត់ចែងបញ្ជូនញត្តិគាំទ្ររបស់គណៈកម្មការទាំង១០ព្រឹទ្ធសភា និងក្រុមសមាជិកាព្រឹទ្ធសភា គាំទ្រយ៉ាងពេញទំហឹងនូវសារសំឡេងពិសេសរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលបានពន្យល់យ៉ាងក្បោះក្បាយអំពីកិច្ចសហប្រតិបត្តិការតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម (CLV-DTA) ឆ្លុះបញ្ចាំងនូវឧត្តមគតិស្នេហាជាតិពិតប្រាកដ សំដៅការពារសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍប្រទេសជាតិ ប្រកបដោយគតិបណ្ឌិត និងទស្សនវិស័យវែងឆ្ងាយ ដើម្បីឧត្តមប្រយោជន៍ជាតិ និងប្រជាពលរដ្ឋគ្រប់រូប។
- បានចាត់ចែងបញ្ជូនញត្តិរបស់អគ្គលេខាធិការដ្ឋាន និងខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា សូមថ្កោលទោសយ៉ាងដាច់អហង្ការចំពោះក្រុមឧទ្ទាមក្រៅច្បាប់ នៅក្រៅប្រទេស ដែលបានធ្វើសកម្មភាព

វិទ្ធង្សនា នាពេលថ្មីៗនេះ ផ្សព្វផ្សាយព័ត៌មានមិនពិត អុជអាល ញុះញង់ បំបែកបំបាក់សង្គមជាតិ សំដៅផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតថ្លែងអំណរព្រះគុណ និងអរគុណរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ នៃព្រះរាជាណាចក្រកម្ពុជា និងផ្ញើជូន**ឯកឧត្តម អនុប្រធានទី១ព្រឹទ្ធសភា ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា** សម្តេចរាជបុត្រីព្រះអនុជ ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដោយ**សម្តេចតេជោ ប្រធានព្រឹទ្ធសភា** បានទទួលសារលិខិតជូនពរដ៏មានអត្ថន័យ និងប្រកបដោយមនោសញ្ចេតនាដ៏កក់ក្តៅបំផុតក្នុងឱកាសខួបចម្រើនជន្មាយុគម្រប់ ៧២ឆ្នាំ ឈានចូល ៧៣ឆ្នាំ របស់**សម្តេចតេជោ ប្រធានព្រឹទ្ធសភា**។
- បានរៀបចំ និងចាត់ចែងបញ្ជូនសេចក្តីជូនដំណឹងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាស្តីពីការជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សាអង្គចៅក្រម ១រូប ជំនួស ឯកឧត្តម **លាង សួគ៌** សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលនឹងត្រូវបញ្ចប់អាណត្តិ។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គោរពជូនៈ
    - **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងឱកាសដ៏មហានក្ខត្តឫក្សថ្លៃថ្លាប្រកបដោយក្តីសោមនស្សរីករាយនៃពិធីចម្រើនជន្មាយុគម្រប់ ៧៣ឆ្នាំ។
    - **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសនៃពិធីចម្រើនជន្មាយុ គម្រប់៧២ឆ្នាំ និង
    - **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចម្រើនជន្មាយុ គម្រប់៧៥ឆ្នាំ។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតរំលែកទុក្ខរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា គោរពជូនៈ
    - ឯកឧត្តម **គង់ សោភ័ណ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់មហាឧបាសកពុទ្ធសាសនូបត្ថម្ភក៍ **ហ៊ុន ហេងគង់** និង
    - លោកស្រី **ជូ លីនដា** ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ ឯកឧត្តម **ណាឌី តាន់** ទីប្រឹក្សា និងជាអតីតអគ្គលេខាធិការរាជរដ្ឋាភិបាលកម្ពុជា។
- បានទទួលពាក្យបណ្តឹងចូល ចំនួន ៨បណ្តឹង ធ្វើកំណត់បង្ហាញពាក្យបណ្តឹង ចំនួន ៧បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធ ចំនួន ៦បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន ៦បណ្តឹង តម្កល់ទុកមិនចាត់ការ ចំនួន ១បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង

ចំនួន ៧បណ្ដឹង។

- បានធ្វើបទបង្ហាញស្ដីពី " រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា" ប្រគេនព្រះសង្ឃ និងជូនលោកគ្រូ អ្នកគ្រូ និងនិស្សិត នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ចំនួន ១១៨នាក់ ដែលបានអញ្ជើញមកទស្សនកិច្ចសិក្សាស្វែងយល់ពីស្ថាប័នព្រឹទ្ធសភា។

## ៣-មុខងារសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំចាត់ចែង និងផ្ដល់សេវាជូនប្រមុខរដ្ឋស្ដីទី នៃព្រះរាជាណាចក្រកម្ពុជា ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

❖ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្ដីទី នៃព្រះរាជាណាចក្រកម្ពុជា** បានអនុញ្ញាតឱ្យឯកឧត្ដម **ដេរ៉េក យីប** (Derek Yip) ឯកអគ្គរដ្ឋទូតថ្មី នៃប្រទេសអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបជូនសារតាំង នៅវិមានព្រឹទ្ធសភា។

❖ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ នៅវិមានព្រឹទ្ធសភា ចំនួន ៣លើក រួមមាន៖

- ឯកឧត្ដម **យូ កូកូឡាំង** (U Ko Ko Hlaing) រដ្ឋមន្ត្រីទទួលបន្ទុកការិយាល័យប្រធានក្រុមប្រឹក្សារដ្ឋបាលរដ្ឋ និងជាបេសកជនពិសេសរបស់ប្រធានក្រុមប្រឹក្សារដ្ឋបាលរដ្ឋ នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។
- ឯកឧត្ដម **គីហារ៉ា មីណូរី** (Kihara Minoru) រដ្ឋមន្ត្រីក្រសួងការពារជាតិជប៉ុន និង
- លោក **អាសាដ យ៉ាកុប** (Asad Yaqub) តំណាងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) នៃធនាគារពិភពលោក ប្រចាំព្រះរាជាណាចក្រកម្ពុជា។

❖ **ឯកឧត្ដម ប្រាក់ សុខុន ប្រធានស្ដីទីព្រឹទ្ធសភា** បានអនុញ្ញាតឱ្យឯកឧត្ដម **វ៉ាឡាសៃ ឡេងសាវ៉ាត់** អនុប្រធានគណៈទាក់ទងបរទេសមជ្ឈិមបក្សប្រជាជនបដិវត្តន៍ឡាវ ចូលជួបសម្ដែងការគួរសម នៅវិមានព្រឹទ្ធសភា។

❖ **ឯកឧត្ដម ប្រាក់ សុខុន អនុប្រធានទី១ព្រឹទ្ធសភា បាន៖**

- អញ្ជើញចូលរួមក្នុងជំនួបសម្ដែងការគួរសម និងពិភាក្សាការងាររវាង **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ជាមួយឯកឧត្ដម **យូ កូកូឡាំង** (U Ko Ko Hlaing) រដ្ឋមន្ត្រីទទួលបន្ទុកការិយាល័យប្រធានក្រុមប្រឹក្សារដ្ឋបាលរដ្ឋ និងជាបេសកជនពិសេសរបស់ប្រធានក្រុមប្រឹក្សារដ្ឋបាលរដ្ឋ នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា នៅវិមានព្រឹទ្ធសភា។
- អនុញ្ញាតឱ្យឯកឧត្ដម **វ៉ាង វិនពីន** (Wang Wenbin) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ នៅសាលប្រជុំពិសេស៣ នៃវិមានព្រឹទ្ធសភា។

- អញ្ជើញជួបពិភាក្សាការងារជាមួយលោកជំទាវ **រ៉េតណូ អិល.ភី ម៉ារស៊ូឌី** (Retno L.P Marsudi) រដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋឥណ្ឌូណេស៊ី នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញភូគីត្រា និង
- អញ្ជើញចូលរួមពិសាអាហារការងារពេលថ្ងៃត្រង់ជាមួយឯកឧត្តម **យូ កូកូឡាំង** (U Ko Ko Hlaing) រដ្ឋមន្ត្រីទទួលបន្ទុកការិយាល័យប្រធានក្រុមប្រឹក្សារដ្ឋបាលរដ្ឋ និងជាបេសកជនពិសេសរបស់ប្រធានក្រុមប្រឹក្សារដ្ឋបាលរដ្ឋ នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា នៅភោជនីយដ្ឋានTopaz។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី២ព្រឹទ្ធសភា បាន៖**

- អនុញ្ញាតឱ្យឯកឧត្តម **ស្តេហ្វេនុស បេន លីអូ** (Stefanus B.A.N Liow) ប្រធានទីភ្នាក់ងារកិច្ចការនីតិប្បញ្ញត្តិប្រចាំតំបន់ នៃសភាតំណាងតំបន់ នៃសាធារណរដ្ឋឥណ្ឌូណេស៊ី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅសាលប្រជុំពិសេស នៃវិមានព្រឹទ្ធសភា និង
- អញ្ជើញចូលរួមក្នុងពិធីពិសាអាហារសាមគ្គីជាមួយលោក **Asad** និងលោកស្រី **Megann** នៅសណ្ឋាគាររ៉ូសវូត ក្នុងអគារវឌ្ឍនៈ រាជធានីភ្នំពេញ។

❖ ឯកឧត្តមបណ្ឌិត **ថែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បាន៖

- អញ្ជើញដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមមិត្តភាពព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជាជាមួយក្រុមប្រឹក្សាសហព័ន្ធ នៃសភាសហព័ន្ធ នៃសហព័ន្ធរុស្ស៊ី ដើម្បីពិនិត្យ និងពិភាក្សាស្វែងយល់អំពីរចនាសម្ព័ន្ធរបស់ក្រុមមិត្តភាពរុស្ស៊ីនីតិកាលទី៤ សិក្សាស្វែងយល់អំពីកញ្ចប់ថវិការបស់ក្រុមមិត្តភាពរុស្ស៊ីនីតិកាលទី៤ រៀបចំផែនការសកម្មភាពការងារក្រុមមិត្តភាពសម្រាប់នីតិកាលទី៥ វឌ្ឍនភាពការងារក្រុមមិត្តភាពរុស្ស៊ីនីតិកាលទី៥ នៅសាលប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា។
- អញ្ជើញចូលរួមពិសាអាហារការងារពេលថ្ងៃត្រង់ជាមួយឯកឧត្តម **យូ កូកូឡាំង** (U Ko Ko Hlaing) រដ្ឋមន្ត្រីទទួលបន្ទុកការិយាល័យប្រធានក្រុមប្រឹក្សារដ្ឋបាលរដ្ឋ និងជាបេសកជនពិសេសរបស់ប្រធានក្រុមប្រឹក្សារដ្ឋបាលរដ្ឋ នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា នៅភោជនីយដ្ឋានTopaz។
- អនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅរាជធានីភ្នំពេញ ចំនួន ២លើក រួមមាន៖
    - លោកជំទាវ **មីលេណា ខារីដាដ ហ្សាល់ឌីវ៉ា ភីដ្រា** (Milena Caridad Zaldivar Piedra) ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋគុយបា ប្រចាំព្រះរាជាណាចក្រកម្ពុជា និង
    - លោក **អ៊ីហ្គ័រ ខារ៉ាវ៉ា** (Igor Karavaev) ភារធារីស្តីទី នៃស្ថានទូតរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា។

❖ ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បាន៖

- អញ្ជើញចូលរួមកិច្ចប្រជុំតាមប្រព័ន្ធនិម្មិត នៅក្នុងក្របខ័ណ្ឌតំបន់អាស៊ី-ប៉ាស៊ីហ្វិក នៃសភាប្រើភាសាបារាំង(APF) ដើម្បីពិភាក្សាអំពីការរៀបចំកិច្ចប្រជុំមហាសន្និបាតតំបន់អាស៊ី-

ប៉ាស៊ីហ្វិក លើកទី១១ (APF-11th) នៅសាលប្រជុំពិសេសកណ្តាលព្រឹទ្ធសភា។

- អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអេចិន្ត្រៃយ៍ហ្វ្រង់កូហ្វូនសីលធម៌ និងក្រុមសីលធម៌ សមាជិកសភា តាមប្រព័ន្ធនិម្មិត នៅសាលប្រជុំពិសេសកណ្តាលព្រឹទ្ធសភា។
- អនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្តែងការគួរសម នៅបន្ទប់ឯកឧត្តមប្រធាន គណៈកម្មការទី៩ព្រឹទ្ធសភា អគារ F ព្រឹទ្ធសភា ចំនួន ២លើក រួមមាន៖
    - លោក **អាត់ស៊ូស៊ី យ៉ូណេហ្សាវ៉ា** (Atsushi Yonezawa) ប្រធានកុងស៊ុលជប៉ុន ប្រចាំខេត្តសៀមរាប និង
    - លោក **ណាកាសិ កិនស៊ូកិ** (Nagase Kensuke) អគ្គទីប្រឹក្សាស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា។

❖ ឯកឧត្តម **ងី ច័ន្ទ្រផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានទទួលជួបពិភាក្សាការងារជាមួយ តំណាងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR) ដឹកនាំដោយលោកស្រី **រួអេដា អិល ហាច** (Roueida El Hage) ដើម្បីផ្លាស់ប្តូរ យោបល់ និងស្វែងយល់អំពីបេសកកម្មការងាររបស់ការិយាល័យឧត្តមស្នងការ នៅក្នុង ព្រះរាជាណាចក្រកម្ពុជា និងបង្កើតកិច្ចសហប្រតិបត្តិការការងារលើវិស័យសិទ្ធិមនុស្ស នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា។

❖ ឯកឧត្តម **ងី ច័ន្ទ្រផល** ប្រធានគណៈកម្មការ១ព្រឹទ្ធសភា ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** ប្រធាន គណៈកម្មការទី២ព្រឹទ្ធសភា ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្តម **ម៉ែន ស៊ីផាន់** អនុប្រធាន គណៈកម្មការទី៩ព្រឹទ្ធសភា និងឯកឧត្តម **ស៊ាក ឡេង** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីអបអរសាទរខួបលើកទី៥៩ ទិវាបុណ្យឯករាជ្យជាតិ នៃសាធារណរដ្ឋ សិង្ហបុរី ដើម្បីរួមចំណែកលើកកម្ពស់ចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អឱ្យកាន់តែរឹងមាំ រវាងកម្ពុជា-សិង្ហបុរី នៅសណ្ឋាគាររ៉ហ្វូហ្វលស៍ ឡឺរ៉ូយ៉ាល់ រាជធានីភ្នំពេញ។

❖ ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិសាអាហារ សាមគ្គីជាមួយឯកឧត្តម **ង្វៀន ហ៊ុយតាំង** (Nguyen Huy Tang) ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋ សង្គមនិយមវៀតណាម ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅស្ថានទូតវៀតណាម រាជធានីភ្នំពេញ។

❖ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុង កិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តកិច្ចសហប្រតិបត្តិការរយៈពេល២ឆ្នាំ ដំណាក់កាល ឆ្នាំ២០២២-២០២៤ រវាងសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ខេត្តព្រៃវែង និងសមាគមសហព័ន្ធនារី ខេត្តដុងថាប់ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅសាលប្រជុំ សាលាខេត្តព្រៃវែង។

- ❖ ឯកឧត្តម **ឈិត សុខុន** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ បានអញ្ជើញចូលរួមក្នុងកិច្ចពិភាក្សាការងារ រវាងឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី២ព្រឹទ្ធសភា ជាមួយឯកឧត្តម **ស្តេហ្វេនុស បេន លីអូ** (Stefanus B.A.N Liow) ប្រធានទីភ្នាក់ងារកិច្ចការនីតិប្បញ្ញត្តិប្រចាំតំបន់ នៃសភាតំណាងតំបន់ នៃសាធារណរដ្ឋឥណ្ឌូណេស៊ី នៅសាលប្រជុំពិសេស នៃវិមានព្រឹទ្ធសភា។
- ❖ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអនុញ្ញាតឱ្យលោក **ណាកាសិ កិនស៊ូកិ** (Nagase Kensuke) អគ្គទីប្រឹក្សាស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា និងសហការីចូលជួបសម្តែងការគួរសម និងផ្លាស់ប្តូរយោបល់លើកិច្ចសហប្រតិបត្តិការនានាដែលជាផលប្រយោជន៍រួម និង
- ❖ ឯកឧត្តមបណ្ឌិត **ឈើវ យីស៊ាង** នាយកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា បានអនុញ្ញាតឱ្យលោក **ណាកាសិ កិនស៊ូកិ** (Nagase Kensuke) ក្នុងឱកាសដែលលោកទើបត្រូវបានតែងតាំងជាអគ្គទីប្រឹក្សាស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅបន្ទប់ទទួលភ្ញៀវរបស់ឯកឧត្តមនាយក អគារក្រហមព្រឹទ្ធសភា។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា គោរពជូនលោកជំទាវ **ផែថងថាន ស៊ីណាវ៉ាត្រា** (Paetongtarn Shinawatra) ដែលត្រូវបានជាប់ឆ្នោតជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រថៃ។
- បានចាត់ចែងបញ្ជូនសារលិខិតថ្លែងអំណរគុណរបស់ឯកឧត្តម **ជិន ថាញ់មិន** (Tran Than Man) ប្រធានរដ្ឋសភា នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដែល**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានអញ្ជើញចូលរួមរំលែកទុក្ខចំពោះមរណភាពរបស់ឯកឧត្តម **ង្វៀន ហ្វ៊ូចុង** អគ្គលេខាធិការ នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម។
- បានចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ឯកឧត្តមនាយឧត្តមសេនីយ៍ជាន់ខ្ពស់ **មីន អោង ឡាំង** (Min Aung Hlaing) ប្រធានក្រុមប្រឹក្សារដ្ឋបាលរដ្ឋ នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងឱកាសដ៏វិសេសវិសាលនៃថ្ងៃខួបកំណើតរបស់**សម្តេចតេជោ ប្រធានព្រឹទ្ធសភា** និង
- បានសហការ និងទាក់ទងជាមួយស្ថានទូតសិង្ហបុរី ស្ថានទូតចិន ស្ថានទូតម៉ាឡេស៊ី ស្ថានទូតព្រុយណេដារូស្សាឡាម ស្ថានទូតឥណ្ឌា ស្ថានទូតថៃ ស្ថានទូតវៀតណាម ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ទីស្តីការគណៈរដ្ឋមន្ត្រី មជ្ឈមណ្ឌលសភាអាស៊ី (PCAsia) មជ្ឈមណ្ឌលកម្ពុជា ៤.0 បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (CADT) វិទ្យាស្ថានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ វិទ្យាស្ថានប្រសិទ្ធ វិទ្យាស្ថានសាន់វ៉ាយស៍ និងក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ។

## ៤-មុខងារអនិទឡ្ស័ស្ថាប័ន

### ៤.១-កិច្ចប្រជុំសំខាន់ៗរបស់ព្រឹទ្ធសភា និងកម្មវិធីផ្សេងៗ៖

- ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បាន៖
  - អញ្ជើញចូលរួមប្រជុំការងារសំខាន់ៗ ដឹកនាំដោយ ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ ព្រឹទ្ធសភា និង
  - អញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា ប្រចាំខែកក្កដា និងទិសដៅការងារខែសីហា ឆ្នាំ២០២៤ នៅសាលខាងជើង ព្រឹទ្ធសភា។

- ឯកឧត្តម **ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បាន៖
  - អញ្ជើញចូលរួមប្រជុំការងារសំខាន់ៗ ដឹកនាំដោយ ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ ព្រឹទ្ធសភា និង
  - អញ្ជើញជាអធិបតីក្នុងពិធីប្រគល់ និងទទួលអំណោយជាកុំព្យូទ័រ ចំនួន ៦០គ្រឿង ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជូនអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តំណាងដោយ ឯកឧត្តម **ទូច យ៉ារ៉ាន់ឌី** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នៅសាលខាងជើងព្រឹទ្ធសភា។

- ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញដឹកនាំប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកក្កដា និងខែសីហា ព្រមទាំងទិសដៅការងារខែកញ្ញា ឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងអគ្គនាយកដ្ឋានស្រាវជ្រាវ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

### ៤.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ៖

- បានបើកប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារបន្ថែម ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺ ប្រាក់ឧបត្ថម្ភធ្វើដំណើរ និងសេវាទំនាក់ទំនងប្រចាំខែសីហា ឆ្នាំ២០២៤ ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ភ្នាក់ងារសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត និងនិវត្តជន នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមរយៈប្រព័ន្ធធនាគារ។
- បានបោះផ្សាយអាណត្តិជំពូក ៦៤ សម្រាប់ចំណាយ និងប្រាក់ឧបត្ថម្ភសម្រាប់ពិធីបុណ្យភ្ជុំបិណ្ឌ ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងប្រាក់ឧបត្ថម្ភបន្ថែម ចំនួន ៥០,០០០៛/នាក់ សម្រាប់ពិធីបុណ្យភ្ជុំបិណ្ឌ ឆ្នាំ២០២៤ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- បានធ្វើបញ្ជីចំណូល-ចំណាយ របាយការណ៍បេឡា និងរបាយការណ៍វិភាគប្រាក់បញ្ញើនៅធនាគារជាតិ នៃកម្ពុជា ប្រចាំខែកក្កដា ឆ្នាំ២០២៤។
- បានបង្វែរប្រាក់វិភាគទានជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម(ប.ស.ស) របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែសីហា ឆ្នាំ២០២៤។
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ១៣៥សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន ៤១០សំណើ។
- បានដោះស្រាយសំណើផ្សេងៗ និងផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា កម្មវិធីផ្សេងៗ និង ជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ៦២សំណើ។
- បានថតចម្លងឯកសារ ចំនួន ១,០៤៣ច្បាប់ អស់ក្រដាស សរុបចំនួន ១៤,៩៤៤សន្លឹក។
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ទាំង ៨ ភូមិភាគ ចំនួន ៩៣លើក ស្មើនឹង ១៨៣នាក់។
- បានរៀបចំ បោសសម្អាត តុបតែងលម្អសាល តាំងលម្អផ្កាមុខអគារក្រហម និងសាលជំនួបភ្ញៀវ ព្រមទាំងផ្តល់សេវាបម្រើភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន ៣៨លើក ស្មើនឹង ៩៤៩នាក់។
- បានទទួលលិខិតចូល ចំនួន ៦៨៣ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង ស្ថាប័នពាក់ព័ន្ធនានា ចំនួន ៩៤ច្បាប់។
- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ៣៧ច្បាប់ ស្មើនឹង ២៤៥នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន ៥ច្បាប់។
- បានចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជន នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប ចំនួន ១១នាក់។
- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន ៣៤លើក និងបានដាំផ្ការាជនី នៅមុខសួនច្បារអគារក្រហម ចំនួន ៦០គុម្ព បានតាំងលម្អផ្កាស្បៃរឿង ក្រោមព្រះឆាយាលក្ខ័ណ៍ នៅមុខស្ថាប័នព្រឹទ្ធសភា ចំនួន ២០០គុម្ព ដើម្បីអបអរសាទរពិធី " **បើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ** " ព្រមទាំងសម្អាតបរិស្ថាន អនាម័យ ក្នុងបរិវេណព្រឹទ្ធសភា ចំនួន ១២លើក។
- បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែសីហា រួមមាន៖
    - មន្ត្រីរាជការក្របខ័ណ្ឌ ចំនួន ៧០៧នាក់ (ប្រុស ៤២០នាក់ ស្រី ២៨៧នាក់)។
    - បុគ្គលិកជាប់កិច្ចសន្យា ចំនួន ៨៤នាក់ (ប្រុស ៤៩នាក់ ស្រី ៣៥នាក់)។

- មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន ៤៩៣នាក់ (ប្រុស ៣០៦នាក់ ស្រី ១៨៧នាក់) និង
- មន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ចំនួន ១១នាក់ និងព្យួរក្រៅក្របខ័ណ្ឌដើម ចំនួន ៣នាក់។

- បានធ្វើលិខិតបង្គាប់ការ ចំនួន ២ច្បាប់ និងសេចក្ដីសម្រេច ចំនួន ៣ច្បាប់។
- បានធ្វើតារាងបញ្ជាក់ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ លិខិតផ្ទត់ផ្ទង់ និងវិញ្ញាបនបត្របញ្ជាក់រយៈពេលបំពេញការងាររដ្ឋ ចំនួន ៥ច្បាប់។
- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ-កូន) ប្រចាំខែសីហា ឆ្នាំ២០២៤ (មន្ត្រីរាជការស្នើសុំបញ្ចូលប្រាក់ឧបត្ថម្ភសម្រាប់ប្រពន្ធ ចំនួន ១នាក់ និងកូន ចំនួន ១នាក់)។
- បានចែកប័ណ្ណសមាជិកបេឡាជាតិសន្តិសុខសង្គម(ប.ស.ស) ជូនសហព័ទ្ធ និងកូន របស់មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ១៧៨ប័ណ្ណ។
- បានបញ្ជូនមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ១៩នាក់ ចូលរួមវគ្គបណ្ដុះបណ្ដាលនៅក្នុងប្រទេស ចំនួន ៤វគ្គ រួមមាន៖
  - វគ្គ "ការកត់ត្រា និងសរសេររបាយការណ៍" និងវគ្គ "ជំនាញភាសាអង់គ្លេស និងទំនាក់ទំនងកម្រិតខ្ពស់" នៅមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី និង
  - វគ្គ "ការវិភាគសារពើពន្ធជំនាន់ទី៤" និងវគ្គ "បច្ចេកទេសក្នុងការវិភាគភូមិសាស្ត្រនយោបាយ" នៅមជ្ឈមណ្ឌលសភាអាស៊ី។
- បានបញ្ជូនមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ៨នាក់ ចូលរួមវគ្គបណ្ដុះបណ្ដាល ចំនួន ១វគ្គ ស្ដីពី "ផែនការ និងសមត្ថភាពក្នុងការកសាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍" នៅសាធារណរដ្ឋប្រជាមានិតចិន។
- បានធ្វើផែនការបណ្ដុះបណ្ដាល និងអភិវឌ្ឍន៍ធនធានមនុស្សរយៈពេល៦ឆ្នាំ (ឆ្នាំ២០២៤-២០៣០) នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានព្រាងរៀបចំផែនការបណ្ដុះបណ្ដាល និងអភិវឌ្ឍន៍ធនធានមនុស្សឆ្នាំ២០២៥។
- ការងារសាងសង់សំណង់ថ្មីៗ ជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ រួមមាន៖
  - បានជួសជុលកែលម្អនៅបន្ទប់ជាន់ក្រោមអគារក្រហមព្រឹទ្ធសភា។
  - បានជួសជុលកែលម្អអគារការិយាល័យសម្រាប់បំពេញការងារជូននាយកដ្ឋានរដ្ឋបាល បណ្ណាល័យ និងសមាគមសង្គហៈមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ។
  - បានរុះរើអគារនាយកដ្ឋានរដ្ឋបាល សាលបណ្ណាល័យ និងសំណង់ក្នុងសួនអ័រគីដេ ដើម្បីត្រៀមសាងសង់អគារថ្មី នៃព្រឹទ្ធសភា។
  - បានធ្វើស្លាកឈ្មោះបន្ទប់ នៅតាមអគារថ្នាក់ដឹកនាំព្រឹទ្ធសភា និងអង្គភាពនានា ចំនួន ៣៤បន្ទប់ និង
  - បានជួសជុលផ្លូវបាក់ស្រុត និងពង្រីកកងចន្ទល់ដើមឈើនៅក្នុងបរិវេណព្រឹទ្ធសភា ចំនួន ៤៣ដើម/កន្លែង។

- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្តាញទឹក បណ្តាញអគ្គិសនី ត្រួតពិនិត្យជណ្តើរយន្ត សត្វកណ្តៀរ រៀបចំ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម ប្រមូលសម្ភារខូច បិទលេខកូដសម្ភារសារពើភ័ណ្ឌ ប្រគល់ និងបំពាក់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន ៣២៥គ្រឿង/លើក។
- បានបំពាក់ស្លាកលេខរថយន្តខ្នាតវែងព្រឹទ្ធសភា ជូនសមាជិកព្រឹទ្ធសភា ចំនួន ២គ្រឿង។
- បានចុះធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ (ព្រឹទ្ធសភា)។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែសីហា ឆ្នាំ២០២៤ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។
- បានធ្វើបទបង្ហាញ និងរបាយការណ៍ស្តីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែសីហា ឆ្នាំ២០២៤។
- បានធ្វើរបាយការណ៍ និងសម្រង់ស្ថិតិស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែសីហា ឆ្នាំ២០២៤ ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងក្រសួងស្ថាប័នពាក់ព័ន្ធនានា និង
- បានបញ្ចូលកាលប្បវត្តិស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាគណៈកម្មការជំនាញទាំង១០របស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែសីហា ឆ្នាំ២០២៤ ក្នុងប្រព័ន្ធកុំព្យូទ័រ ចំនួន ១៥ច្បាប់។

### ៤.៣-ការងារសេវាច្បាប់៖

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស សារាចរណែនាំ របាយការណ៍ សេចក្តីជូនដំណឹង និងលិខិតផ្សេងៗ ចំនួន ៥ច្បាប់ ពីក្រសួង និងស្ថាប័ននានា។
- បានទទួលសេចក្តីព្រាងច្បាប់ ចំនួន ១ច្បាប់ ពីរដ្ឋសភា ព្រមទាំងបានចែក និងថ្វាយគ្រប់សមាជិក សមាជិកាព្រឹទ្ធសភា។
- បានធ្វើសេចក្តីសម្រេចស្តីពី ការកែសម្រួលសមាសភាពក្រុមជនបង្គោលប្រឆាំងអំពើពុករលួយរបស់ព្រឹទ្ធសភា នីតិកាលទី៥។
- បានថតចម្លងសេចក្តីសម្រេចស្តីពី តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការទាំង១០ព្រឹទ្ធសភា និងក្រុមសមាជិកាព្រឹទ្ធសភា នីតិកាលទី៥ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា។
- បានតាមដានដំណើរការវិវឌ្ឍន៍សម័យប្រជុំរបស់រដ្ឋសភា។
- បានផ្តល់សេវារដ្ឋបាល បច្ចេកទេស ព័ត៌មាន ពិធីការ ទំនាក់ទំនងការងារ ជូនគណៈកម្មការទាំង១០ និងក្រុមនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្ម និងកម្មវិធីផ្សេងៗ ចំនួន ១១៥លើក និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបុគ្គលជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុល នៅព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

### ៤.៤-ការងារស្រាវជ្រាវ៖

- បានធ្វើជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ ចំនួន ១ច្បាប់។
- បានផលិតឯកសារជំនួយស្មារតី និងធ្វើបទបង្ហាញជូនគណៈកម្មការទី៧ព្រឹទ្ធសភាស្តីពី ការវាយតម្លៃការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យទេសចរណ៍ ដោយផ្តោតលើការអនុវត្តគោលនយោបាយពាក់ព័ន្ធចីរភាពបរិស្ថាន និងគោលនយោបាយ និងបញ្ហាប្រឈមក្នុងការគ្រប់គ្រង ក៏ដូចជាការរៀបចំយន្តការនានាក្នុងស្រុក និងតំបន់។
- បានតាមដាន និងសិក្សាស្រាវជ្រាវលើ៖
    - សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២៥។
    - សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។
    - ការអនុវត្តការធ្វើកំណែទម្រង់គោលនយោបាយចំណូល-ចំណាយ និង
    - វឌ្ឍនភាព នៃការអនុវត្តរបស់រាជរដ្ឋាភិបាលអំពីការធ្វើវិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យនានា។
- បានតាមដាន និងចងក្រងឯកសារគោលនយោបាយជាតិស្តីពី ការអភិវឌ្ឍវិស័យយានយន្តអគ្គិសនីកម្ពុជា ឆ្នាំ២០២៤-២០៣០។
- បន្តចងក្រងទិន្នន័យលិខិតបទដ្ឋានគតិយុត្តតាមវិស័យរបស់គណៈកម្មការនានា។
- បានផលិត និងសង្ខេបលទ្ធផលការប្រមូលចំណូលពន្ធក្នុងស្រុក ប្រចាំត្រីមាសទី១ ឆ្នាំ២០២៤។
- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច ប្រចាំសប្តាហ៍ក្នុងខែសីហា ឆ្នាំ២០២៤ ចំនួន ៤ច្បាប់។
- បានធ្វើព័ត៌មានកិច្ចការសភាបញ្ចូលក្នុងសម្រង់សង្ខេបព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ចំនួន ២៥៣ព័ត៌មាន។
- បានស្រង់ឯកសារពីក្នុងរាជកិច្ច និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (រាជកិច្ចពីលេខ ៥៤-៦០ ឆ្នាំ២០២៣)។

### ៤.៥-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា ចំនួន ២៧លើក។
- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងសកម្មភាពការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធ Facebook, Instagram, X (Former Twitter), Youtube និងTiktok ចំនួន ១,២២២លើក។
- បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា

លើគេហទំព័រព្រឹទ្ធសភា ចំនួន ២១៤ប្រធានបទ។

- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុងឆានែលតេឡេក្រាម ព័ត៌មានប្រចាំថ្ងៃ ចំនួន ១,៩០៩ ប្រធានបទ។
- បានអញ្ជើញអ្នកព័ត៌មានទូរទស្សន៍ជាតិកម្ពុជាចូលយកព័ត៌មានក្នុងជំនួបសម្ដែងការគួរសម និង ពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ ព្រមទាំងកម្មវិធីផ្សេងៗ ចំនួន ១៥លើក។
- បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការ ទាំង១០ ក្រុមភូមិភាគទាំង៨ និងក្រុមយន្តការនានារបស់ព្រឹទ្ធសភា នៅខ្លោងទ្វារធំព្រឹទ្ធសភា ចំនួន ២១លើក។
- បានផលិត និងផ្សព្វផ្សាយទស្សនាវដ្ដីប្រចាំខែសីហា ឆ្នាំ២០២៤ ចំនួន ៨០០ក្បាល។
- បានផលិតព្រឹត្តិបត្រស្ដីពី បច្ចេកវិទ្យាព័ត៌មាន ប្រចាំខែសីហា ឆ្នាំ២០២៤ ចំនួន ១ច្បាប់។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ីនធឺណែត ពង្រឹងពង្រីកការផ្គត់ផ្គង់ និងជួសជុល ឧបករណ៍ សម្ភារ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញ បច្ចេកវិទ្យាព័ត៌មាន ចំនួន ៧៣គ្រឿង/លើក។
- បានរៀបចំប្រព័ន្ធស្ទូឌីយ៉ូ ប្រព័ន្ធសំឡេង ប្រព័ន្ធមេក្រូហ្វូន ប្រព័ន្ធរូបភាព ប្រព័ន្ធកាមេរ៉ា និង ប្រព័ន្ធប្រជុំនិម្មិត ឬប្រព័ន្ធប្រជុំពីចម្ងាយ(Digital) ក្នុងជំនួបសម្ដែងការគួរសម និងពិភាក្សាការងារ ជាមួយភ្ញៀវជាតិ-អន្តរជាតិ ព្រមទាំងកិច្ចប្រជុំសំខាន់ៗរបស់ព្រឹទ្ធសភា ចំនួន ៣៧លើក។
- បានរៀបចំកម្មវិធីទទួលពាក្យបណ្ដឹងព្រឹទ្ធសភាអេឡិចត្រូនិច (Mobile Application) និងយុទ្ធសាស្ត្រ ផ្សព្វផ្សាយ។
- បានរៀបចំបំប្លែងកាសែតវីដេអូចាស់ៗរបស់ព្រឹទ្ធសភា ទៅជាប្រភេទវីដេអូឌីជីថល ដើម្បីរក្សាទុក ក្នុងប្រព័ន្ធទិន្នន័យ។
- បានទទួលឯកសារ សៀវភៅច្បាប់ និងសៀវភៅជំនាញផ្សេងៗ និងទស្សនាវដ្ដី ចំនួន ១៨ក្បាល ព្រមទាំងបានអ៊ុតក្របសៀវភៅ ចំនួន ៥៦ក្បាល។
- បានផ្សព្វផ្សាយឯកសាររបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារច្បាប់ ឯកសារ ជំនាញផ្សេងៗ និងសៀវភៅជា E-Book តាម www.elibrary.senate.gov.kh ចំនួន ១,៣៣០ក្បាល ដែលមានសាធារណជនចូលអាន ចំនួន ១,០១៨នាក់ និង
- បានផ្សព្វផ្សាយឯកសារ និងសៀវភៅដែលមាននៅក្នុងបណ្ណាល័យព្រឹទ្ធសភា ក្នុងផេក TikTok របស់ បណ្ណាល័យព្រឹទ្ធសភា (មាន Follower ចំនួន ២៤នាក់ និងអ្នក Like ចំនួន ១,៧០០នាក់)។

**៤.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖**

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្ដែងការគួរសម ពិភាក្សាការងារ និង ពិធីផ្សេងៗ ចំនួន ៣២លើក។

- បានរៀបចំសារលិខិតជូនពរ លិខិតរំលែកទុក្ខ និងលិខិតថ្លែងអំណរព្រះគុណ ទូលថ្វាយ **ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងឥស្សរជនជាន់ខ្ពស់ ថ្នាក់ដឹកនាំតាមក្រសួង ស្ថាប័ននានា ចំនួន ៨លិខិត។
- បានរៀបចំបែបបទស្នើសុំលិខិតឆ្លងដែនការទូតថ្មី ជូនមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ១លើក ស្មើនឹង ៧នាក់។
- បានបកប្រែប្រវត្តិរូបរបស់សមាជិកព្រឹទ្ធសភា ជាភាសាបារាំង ចំនួន ១ច្បាប់។
- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិប្រចាំខែសីហា ឆ្នាំ២០២៤ ចំនួន ១ច្បាប់។
- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន ៨ច្បាប់ និង
- បានដាក់តាំងព្រះឆាយាល័ក្ខណ៍ **ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា អមដោយហ្វុងអក្សរ នៅខាងមុខស្ថាប័នព្រឹទ្ធសភា ដើម្បីអបអរសាទរពិធី " **បើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ** "។

### ៤.៧-ការងារអគ្គាធិការដ្ឋាន៖

- បានសិក្សារបាយការណ៍ និងកម្រងសំណួរ អំពីការងារសង្គមកិច្ច និងការផ្តល់សេវារបស់នាយកដ្ឋាននានា ចំណុះអគ្គនាយកដ្ឋានទាំង៥ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែសីហា ឆ្នាំ២០២៤ ចំនួន ២២លើក។
- បានប្រមូល និងធ្វើរបាយការណ៍ជាមួយនាយកដ្ឋានផែនការ និងសរុប នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ណសារដ្ឋាន ស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវាប្រចាំខែសីហា ឆ្នាំ២០២៤។
- បានចុះត្រួតពិនិត្យវត្តមានដាក់ស្តែងតាមនាយកដ្ឋាននានា ប្រចាំខែសីហា ចំនួន ២លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមានដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានជាប្រចាំថ្ងៃ។
- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមានប្រចាំថ្ងៃ ចំនួន ៤៤លើក ប្រចាំសប្តាហ៍ ចំនួន ៤លើក និងប្រចាំខែសីហា ឆ្នាំ២០២៤ ដែលគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានជាប្រចាំថ្ងៃ។
- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-ទិសដៅការងារខែកញ្ញា ឆ្នាំ២០២៤

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ចំនួន ២ច្បាប់៖
  - ១- សេចក្តីព្រាងច្បាប់ស្តីពី ប្រព័ន្ធទឹកកខ្វក់ និង
  - ២- សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគី នៃកិច្ចព្រមព្រៀងស្តីពី ការទទួលយកបទប្បញ្ញត្តិបច្ចេកទេសរួមនៃអង្គការសហប្រជាជាតិ សម្រាប់យានយន្ត បរិក្ខារ និងគ្រឿងបន្លាស់ដែលអាចបំពាក់ និង/ឬប្រើប្រាស់ទៅលើ យានយន្ត និងលក្ខខណ្ឌសម្រាប់ការទទួលស្គាល់ទៅវិញទៅមក នៃការផ្តល់អនុលោមភាព ដោយឈរលើមូលដ្ឋាន នៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិ។
- ខុទ្ទកាល័យថ្នាក់ដឹកនាំទាំង៣ ការិយាល័យជំនួយការគណៈកម្មការទាំង១០ ក្រុមភូមិភាគ និង ក្រុមសមាជិកាព្រឹទ្ធសភា ត្រៀមធ្វើរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី១ និងលើកទី២ នីតិកាលទី៥។

### ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបសវនាការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងការចុះបេសកកម្ម ដើម្បីតាមដាន ការអនុវត្តច្បាប់ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ក្នុងរយៈពេលវិស្សមកាល៣ខែ ចាប់ពីថ្ងៃទី២ ខែកក្កដា ដល់ថ្ងៃទី២ ខែតុលា ឆ្នាំ២០២៤ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

### ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋនៅមូលដ្ឋាន ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ចុះពិនិត្យ វឌ្ឍនភាព នៃការអភិវឌ្ឍ នៅថ្នាក់ក្រោមជាតិ ចូលរួមពិធីសាសនា និងពិធីផ្លូវការផ្សេងៗនៅ រាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។
- ត្រៀមផ្តល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន ជួបសំណេះសំណាល និងចូលរួមកម្មវិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា រួមមាន៖
  - ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១៖
    - អញ្ជើញចុះបំពេញការងារមូលដ្ឋាន នៅខណ្ឌចំការមន រាជធានីភ្នំពេញ និង
    - អញ្ជើញចូលរួមវេទិកាស្តីពី ស្វែងរកដំណោះស្រាយ បញ្ហាប្រឈម និងសំណូមពរ នៅមូលដ្ឋាន រាជធានីភ្នំពេញ។
  - ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ និងទី៤ អញ្ជើញជួបសំណេះសំណាលជាមួយ ក្រុមប្រឹក្សាឃុំ-សង្កាត់ នៅក្រុងកំពង់ចាម ស្រុកកំពង់សៀម ស្រុកកោះសូទិន ខេត្តកំពង់ចាម និងក្រុងបាត់ដំបង ស្រុកសង្កែ ខេត្តបាត់ដំបង។

- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ អញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាល នៅស្រុកទឹកឈូ ខេត្តកំពត និង
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ អញ្ជើញចូលរួមវេទិកាកិច្ចប្រជុំពិគ្រោះយោបល់ និងសំណេះសំណាលសួរសុខទុក្ខជាមួយអង្គបោះឆ្នោត និងប្រជាពលរដ្ឋ នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង។

- ត្រៀមផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចូលរួមទិវាប្រកាសរដ្ឋធម្មនុញ្ញ និង
- ត្រៀមផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមពិធីបុណ្យកាន់បិណ្ឌ និងបុណ្យភ្ជុំបិណ្ឌ។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ។
- ត្រៀមរៀបចំដំណើរទស្សនកិច្ចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋកូរ៉េ និងដំណើរទស្សនកិច្ចទៅកាន់ប្រទេសជាមិត្តមួយចំនួនទៀត។
- ត្រៀមរៀបចំជូនគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា៖
  - អញ្ជើញចូលរួមវេទិកាសមាជិកសភាអាស៊ី-ប៉ាស៊ីហ្វិកលើកទី៨ ស្តីពី សុខភាព (APPFGH-8$^{th}$) នៅប្រទេសវ៉ានូទូ។
  - អញ្ជើញទៅបំពេញទស្សនកិច្ចការងារនៅព្រឹទ្ធសភាបារាំង នៃសាធារណរដ្ឋបារាំង។
  - អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី កិច្ចការសង្គម និងវប្បធម៌ នៃសភាតំបន់អាស៊ី (APA) នៅសហព័ន្ធរុស្ស៊ី។
  - អញ្ជើញចូលរួមប្រជុំពេញអង្គលើកទី១១ នៃសភាអន្តរជាតិ ដើម្បីភាពអត់ឱន និងសន្តិភាព (IPTP) ដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ នាខែវិច្ឆិកា ឆ្នាំ២០២៤ និង
  - ត្រៀមធ្វើជាម្ចាស់ផ្ទះសន្និសីទអន្តរជាតិគណបក្សនយោបាយ នៅអាស៊ី-ប៉ាស៊ីហ្វិក ដែលមានជាង៣៨០គណបក្ស និងមកពីជាង៥២ប្រទេសចូលរួម និង
  - រៀបចំកិច្ចប្រជុំមហាសន្និបាតតំបន់អាស៊ី-ប៉ាស៊ីហ្វិកលើកទី១១ នៃសភាប្រើភាសាបារាំង (APF-11$^{th}$) ។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- ត្រៀមបន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានារួមមាន ការងារសាងសង់ ការជួសជុល ថែទាំកែលម្អបរិស្ថាន អនាម័យ សួនច្បារ ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព។
- ត្រៀមផ្តល់សេវាផ្គត់ផ្គង់សម្ភារ ថវិកា មធ្យោបាយដឹកជញ្ជូន និងសេវាសំខាន់ៗផ្សេងទៀតជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនឱ្យបានទាន់ពេលវេលា និងល្អប្រសើរ និង

- ត្រៀមបញ្ជូនមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចូលរួមសិក្ខាសាលាស្តីពី " សេដ្ឋកិច្ចបើកចំហសម្រាប់បណ្តាប្រទេសដែលមានគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ " នៅសាធារណរដ្ឋប្រជាមានិតចិន។

## III-សេចក្តីសន្និដ្ឋាន

ខែសីហា ជាខែទី២ នៃវិស្សមកាលរយៈពេលបីខែរបស់ព្រឹទ្ធសភា ថ្នាក់ដឹកនាំ គណៈកម្មការ ក្រុមភូមិភាគនានា បានបង្កើនសកម្មភាពការងារក្នុងការបំពេញមុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា ព្រមទាំងមុខងារតំណាង ដោយបានចុះបេសកកម្ម និងជួបពិភាក្សាការងារ ជាមួយក្រសួង ស្ថាប័ន អាជ្ញាធរជាតិ និងអាជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីស្វែងយល់អំពីលទ្ធផលការងារ សម្រេចបាន វឌ្ឍនភាពការងារកំពុងអនុវត្ត ទិសដៅការងារបន្ត និងបញ្ហាប្រឈមនានា។

ក្នុងបរិការណ៍នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបង្កើនស្មារតីសាមគ្គីភាព នវានុវត្តន៍ បុរេសកម្ម លើគ្រប់ការដ្ឋានការងារ ដើម្បីផ្តល់សេវាឱ្យទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ ជូនសមាជិកព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនសម្រេចបានលទ្ធផលល្អ។

ចំពោះការងារក្នុងស្ថាប័ន អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក៏បានផ្តោតការយកចិត្តទុកដាក់លើ ការងារការទូតសភា និងការកសាងហេដ្ឋារចនាសម្ព័ន្ធ ពិសេសការកសាងអគារថ្មី នៃព្រឹទ្ធសភា ដែលកំពុងដំណើរការសាងសង់។

ថ្ងៃសុក្រ ២កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី ៤ ខែ តុលា ឆ្នាំ២០២៤

**អគ្គលេខាធិការ**

**ឡាយ សំកុល**